ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អង្គភាពគ្រប់គ្រងកម្មវិធីAPTERR

លេខ : ..០៣...../APTERR

## សេចក្តីជូនដំណឹង (លើកទី២)
## ស្តីពីការអញ្ជើញចូលរួមដេញថ្លៃការផ្គត់ផ្គង់អង្ករ
## សម្រាប់អនុវត្តកម្មវិធីអង្ករបម្រុងសង្គ្រោះបន្ទាន់អាស៊ានបូកបី APTERR

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (អង្គភាពគ្រប់គ្រងកម្មវិធីអង្ករបម្រុងសង្គ្រោះបន្ទាន់អាស៊ានបូកបី-APTERR) សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាស ឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យបានជ្រាបថា (អង្គភាពគ្រប់គ្រងកម្មវិធីអង្ករបម្រុងសង្គ្រោះបន្ទាន់អាស៊ានបូកបី-APTERR) នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ (លើកទី២) ដើម្បីជ្រើសរើសអ្នកផ្គត់ផ្គង់អង្ករសម្រាប់អនុវត្តកម្មវិធីអង្ករបម្រុងសង្គ្រោះបន្ទាន់អាស៊ានបូកបីAPTERR។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (អង្គភាពគ្រប់គ្រងកម្មវិធីអង្ករបម្រុងសង្គ្រោះបន្ទាន់អាស៊ានបូកបី-APTERR) បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅផ្នែកលទ្ធកម្មនៃអង្គភាពគ្រប់គ្រងកម្មវិធីAPTERR (អង្គភាពលទ្ធកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) ដែលមានអាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី...២៣...ខែ.កក្កដា.ឆ្នាំ២០២៦ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ ០៦០ ២១ ២១ ៨៣)។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ យ៉ាងយូរបំផុតត្រឹមថ្ងៃទី..១០......ខែ..សីហា..ឆ្នាំ២០២៦ វេលាម៉ោង...១៥:០០'...។

ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមអាសយដ្ឋាន ខាងលើ វេលាម៉ោង....១៥:០០.....ថ្ងៃទី.....១០.....ខែ..សីហា.....ឆ្នាំ២០២៦។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ។

ថ្ងៃ ៧.............កើត ខែ.................ឆ្នាំមមី អដ្ឋស័ក្ត ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី ..២២.........ខែ កក្កដា...ឆ្នាំ២០២៦

**អគ្គលេខាធិការ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**និងជានាយកកម្មវិធី** APTERR

**ចម្លងជូន៖**

-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

-អង្គភាពប្រឆាំងអំពើពុករលួយ

-ឯកសារ កាលប្បវត្តិ